s

# ជំងឺ COVID-19

## នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles
## ការត្រួតពិនិត្យតាមច្រកចូល

ការត្រួតពិនិត្យតាមច្រកចូលគឺជាវិធីសាស្ត្រមួយដើម្បីជួយកាត់បន្ថយការរីករាលដាលនៃជំងឺ COVID-19។ វាត្រូវបានតម្រូវជាចាំបាច់ដោយ Cal/OSHA សម្រាប់បុគ្គលិកទាំងអស់។ វាក៏ត្រូវបានតម្រូវជាចាំបាច់ដោយនាយកដ្ឋានសុខភាពសាធារណៈនៃរដ្ឋកាលីហ្វ័រញ៉ា (CDPH) សម្រាប់ភ្ញៀវទាំងអស់ដែលមកកាន់មណ្ឌលថែទាំសុខភាព (AFL 20-38.7) ផងដែរ។ ឯកសារនេះផ្តល់នូវសេចក្តីណែនាំបន្ថែមសម្រាប់ទីតាំងអាជីវកម្ម ទាក់ទងនឹងការត្រួតពិនិត្យតាមច្រកចូល។ សូមយោងទៅលើ សេចក្តីណែនាំសម្រាប់អាជីវកម្មនិងម្ចាស់អាជីវកម្ម សម្រាប់គំរូអនុវត្តល្អបំផុតផ្សេងទៀតដើម្បីទប់ស្កាត់ជំងឺ COVID-19។

បទដ្ឋានបណ្តោះអាសន្នបន្ទាន់នៃការទប់ស្កាត់ជំងឺ COVID-19 (ETS) របស់ Cal/OSHA តម្រូវឱ្យម្ចាស់អាជីវកម្មឬកន្លែងការងារទាំងឡាយរៀបចំបង្កើត និងអនុវត្តនីតិវិធីសម្រាប់ការត្រួតពិនិត្យបុគ្គលិកទាំងឡាយ ចំពោះរោគសញ្ញានៃជំងឺ COVID-19។

ជម្រើសនៃការត្រួតពិនិត្យតាមច្រកចូល រួមមាន៖

- ដោយឱ្យបុគ្គលទាំងអស់ វាយតម្លៃរោគសញ្ញាផ្ទាល់ខ្លួនរបស់ពួកគេពេលនៅផ្ទះ មុនពេលបង្ហាញខ្លួននៅកន្លែងធ្វើការ ឬឡើងជិះមធ្យោបាយធ្វើដំណើររួមគ្នា
- ដោយប្រើប្រាស់ស្លាកសញ្ញានៅតាមច្រកចូលកន្លែងធ្វើការ ដែលបញ្ជាក់ថាបុគ្គលទាំងឡាយណាដែលមានរោគសញ្ញា និង/ឬទទួលលទ្ធផលវិជ្ជមាននៃការធ្វើតេស្តរកមេរោគ COVID-19 មិនត្រូវចូលទៅទីតាំងនោះទេ។
- ដោយបំពេញការត្រួតពិនិត្យដោយផ្ទាល់នៅនឹងកន្លែងធ្វើការ[1]

បុគ្គលទាំងឡាយមិនគួរចូលទៅកាន់កន្លែងធ្វើការទេ ប្រសិនបើពួកគេ៖

- មានគ្រុនក្តៅ ឬរោគសញ្ញានានានៃជំងឺ COVID-19[2]
- ត្រូវបានតម្រូវឱ្យដាក់ខ្លួនឱ្យនៅដាច់ដោយឡែកនាពេលបច្ចុប្បន្ន ដោយផ្អែកទៅលើសេចក្តីបង្គាប់នៃការដាក់ខ្លួនឱ្យនៅដាច់ដោយឡែករបស់មន្ត្រីសុខាភិបាល
- ជាបុគ្គលិកដែលមានទំនាក់ទំនង ហើយដែលត្រូវតម្រូវចាំបាច់ឱ្យផ្អាកពីការងារ ដោយផ្អែកទៅលើបទដ្ឋានរបស់ Cal-OSHA។

កំណត់សម្គាល់៖ តម្រូវការនៃការចូលទៅកាន់មណ្ឌលថែទាំសុខភាពអាចមានភាពខុសគ្នា។ ទីតាំងទាំងឡាយគួរតែយោងទៅលើលិខិតសម្រាប់ទីតាំងគ្រប់ប្រភេទ (AFLs) របស់ CDPH ដែលពាក់ព័ន្ធ។

---

[1] ដោយផ្អែកទៅលើបទដ្ឋាន ETS របស់ Cal-OSHA ប្រសិនបើកន្លែងការងារជ្រើសរើសធ្វើការត្រួតពិនិត្យដោយផ្ទាល់ ហើយនៅខាងក្នុងអគារ ទាំងអ្នកពិនិត្យនិងបុគ្គលិក ត្រូវតែពាក់ម៉ាស់។ ប្រសិនបើមានការវាស់សីតុណ្ហភាព គឺត្រូវតែប្រើប្រាស់ឧបករណ៍វាស់កម្តៅដែលមិនប៉ះពាល់ដោយផ្ទាល់។ កំណត់សម្គាល់៖ ការវាស់សីតុណ្ហភាពជាក់ស្តែងនៅច្រកចូល មិនត្រូវបានតម្រូវជាចាំបាច់នោះទេ។

[2] រោគសញ្ញានៃជំងឺ COVID-19 រាប់បញ្ចូលទាំង គ្រុនក្តៅឬគ្រុនរងា ក្អក ដង្ហើមខ្លីឬពិបាកដកដង្ហើម លែងដឹងរសជាតិឬក្លិនថ្មីៗ ឈឺសាច់ដុំឬឈឺខ្លួន ឈឺក្បាល ឈឺបំពង់ក ចង្អោរចង់ក្អួតឬក្អួត រាគរូស តឹងច្រមុះឬហៀរសំបោរ ឬក៏មានអារម្មណ៍អស់កម្លាំង។